សុខភាព និងជីវិត
កាន់តែប្រសើរ



# AIA ACCIDENTCARE

## ការពារធនធានដ៏មានតម្លៃបំផុតរបស់ក្រុមហ៊ុនជាមួយនឹង ដំណោះស្រាយការពារលើគ្រោះថ្នាក់ចៃដន្យទាំងអស់

បុគ្គលិក គឺជាទ្រព្យសកម្មដែលមានតម្លៃបំផុតរបស់ក្រុមហ៊ុន។ បុគ្គលិក ទាំងអស់ត្រូវការពារលើសពីសុវត្ថិភាពរាងកាយរបស់ពួកគេដោយសារតែព្រឹត្តិការណ៍អកុសលផ្សេងៗអាចនឹងកើតឡើងគ្រប់ពេលទាំងអំឡុងពេល និងក្រៅម៉ោងធ្វើការ ដូចនេះវាជាការចាំបាច់ដែលបុគ្គលិកមានទេពកោសល្យនៃក្រុមហ៊ុននីមួយៗទទួលបានការការពារផ្នែកហិរញ្ញវត្ថុប្រចាំថ្ងៃដើម្បីធានាការថែទាំដ៏ទូលំទូលាយបំផុតសម្រាប់សុខភាព និងសន្តិភាពផ្លូវចិត្តទាំងមូលរបស់ពួកគេ។

ដូចនេះហើយទើប **AIA AccidentCare** ត្រូវបានបង្កើតឡើងដើម្បីធានាថាបុគ្គលិកទាំងអស់ត្រូវបានការពារជាមួយនឹងដំណោះស្រាយដ៏ទូលំទូលាយតាមរយៈនិយោជករបស់ពួកគេ។

# ហេតុអ្វីជ្រើសរើស AIA AccidentCare?

## AIA AccidentCare នឹងមិនមានសារៈសំខាន់នោះទេ ប្រសិនបើយើងពិតជាអាចទាយថានឹងមានអ្វីអាចកើតឡើងបាន។

**AIA AccidentCare** គឺជាផលិតផលធានារ៉ាប់រងបន្ថែម ដែលអាចឲ្យបុគ្គលិករបស់អ្នកទទួលបានការការពារលើសពីអត្ថប្រយោជន៍សុខភាពទូទៅ។ គោលបំណងរបស់យើងគឺដើម្បីផ្តល់នូវសំណាញ់សុវត្ថិភាពដ៏ញឹកមួយការពារបុគ្គលិករបស់អ្នក និងក្រុមគ្រួសាររបស់ពួកគេពីភាពលំបាកផ្នែកហិរញ្ញវត្ថុក្នុងអំឡុងពេលដែលពួកគេជួបស្ថានភាពលំបាកណាមួយ។ នេះជាមូលហេតុដែលអ្នកជា និយោជក គួរតែពិចារណា **AIA AccidentCare** ដែលមិនមែនជាដំណោះស្រាយបន្ទាប់បន្សំនោះទេ ប៉ុន្តែជាដំណោះស្រាយដ៏ចាំបាច់។

# អត្ថប្រយោជន៍សង្ខេប

### មរណភាពដែលបង្កដោយគ្រោះថ្នាក់ចៃដន្យ

ចំនួនទឹកប្រាក់ធានារ៉ាប់រងសរុប **100%** នឹងត្រូវបានទូទាត់សងប្រសិនបើបុគ្គលិកដែលទទួលបានការធានារ៉ាប់រងទទួលមរណភាពដែលបណ្តាលមកពីគ្រោះថ្នាក់ចៃដន្យ។

### ពិការភាពដែលបង្កដោយគ្រោះថ្នាក់ចៃដន្យ

ពិការភាពដោយផ្នែក ឬពិការភាពទាំងស្រុងរហូតដល់ **26 ករណី**ដែលបង្កដោយគ្រោះថ្នាក់ចៃដន្យត្រូវបានធានារ៉ាប់រង។

### ការព្យាបាលដែលបង្កដោយគ្រោះថ្នាក់ចៃដន្យ

- ធានារ៉ាប់រងទៅលើការព្យាបាលដែលបណ្តាលមកពីគ្រោះថ្នាក់ចៃដន្យដែលបានកំណត់មួយចំនួន ថ្លៃមន្ទីរពេទ្យ និងសេវាថែទាំដែលមានអាជ្ញាប័ណ្ណត្រឹមត្រូវ។
- ធានារ៉ាប់រងលើការចំណាយព្យាបាលដែលនៅសេសសល់បន្ទាប់ពីទទួលប្រាក់សំណងពីរបបសន្តិសុខសង្គម អត្ថប្រយោជន៍បន្ថែម ឬបណ្ណធានារ៉ាប់រងផ្សេងៗរួច។

# ឧទាហរណ៍

ក្រុមហ៊ុន កខគ បានស្វែងយល់ និងចាត់ទុក **AIA AccidentCare** ជាដំណោះស្រាយដ៏ចាំបាច់សម្រាប់និយោជិតរបស់ពួកគេ។ ពួកគេសម្រេចចិត្តទិញការថៃទាំដ៏ទូលំទូលាយបំផុតនេះសម្រាប់បុគ្គលិកចំនួន **100** នាក់ ដោយជឿថានេះគឺជាដំណោះស្រាយដែលរួមបញ្ចូលទាំងអស់ទាំងការការពារសុខភាពទូទៅ និងសន្តិភាពផ្លូវចិត្តរបស់ពួកគេជាពិសេសនៅពេលដែលមានហេតុការណ៍អកុសលកើតឡើង។

## កញ្ចប់អត្ថប្រយោជន៍ AIA AccidentCare ដែលក្រុមហ៊ុន ABC ទទួលយកការពារបុគ្គលិក

| អត្ថប្រយោជន៍ | នាយកប្រតិបត្តិជាន់ខ្ពស់ | អ្នកគ្រប់គ្រងថ្នាក់កណ្តាល | និយោជិតទូទៅ |
|---|---|---|---|
| I. **អត្ថប្រយោជន៍លើមរណភាពដែលបង្កដោយគ្រោះថ្នាក់ចៃដន្យ** (ការស្លាប់ដោយសារគ្រោះថ្នាក់ចៃដន្យគ្រប់ប្រភេទ) | **50,000** ដុល្លារអាមេរិក | **30,000** ដុល្លារអាមេរិក | **25,000** ដុល្លារអាមេរិក |
| II. **អត្ថប្រយោជន៍លើពិការភាពដែលបង្កដោយគ្រោះថ្នាក់ចៃដន្យ** (ពិការភាពដោយផ្នែក និងទាំងស្រុង) | **50,000** ដុល្លារអាមេរិក | **30,000** ដុល្លារអាមេរិក | **25,000** ដុល្លារអាមេរិក |
| III. **អត្ថប្រយោជន៍លើការព្យាបាលដែលបង្កដោយគ្រោះថ្នាក់ចៃដន្យ** (ការព្យាបាលវេជ្ជសាស្ត្រចាំបាច់មួយចំនួន និងថ្លៃព្យាបាលដែលនៅសេសសល់បន្ទាប់ពីទទួលបានការទូទាត់សងពីរបបសន្តិសុខសង្គម ឬអត្ថប្រយោជន៍បន្ថែម ឬការធានារ៉ាប់រងផ្សេងៗទៀត) | **5,000** ដុល្លារអាមេរិក | **3,000** ដុល្លារអាមេរិក | **US$ 2,500** ដុល្លារអាមេរិក |

## តើបុគ្គលិកនឹងទទួលបានអត្ថប្រយោជន៍អ្វីខ្លះពី AIA AccidentCare

| ករណី | អត្ថប្រយោជន៍និយោជិត |
|---|---|
| **អ្នកស្រី សុថារ៉ា មានអាយុ 29 ឆ្នាំ** ជានិយោជិតទូទៅ។ នាងបានរងរបួសដោយគ្រោះថ្នាក់មួយអំឡុងពេលទៅធ្វើការ។ | បន្ទាប់ពីបញ្ជូនទៅមន្ទីរពេទ្យ ថ្លៃព្យាបាលរបស់ សុថារ៉ា មានតម្លៃ **300** ដុល្លារអាមេរិក ហើយ **អេ អាយ អេ ខេមបូឌា** ផ្តល់សំណងដល់សុថារ៉ា ចំនួន **300** ដុល្លារអាមេរិក ស្ថិតនៅក្រោមអត្ថប្រយោជន៍លើការព្យាបាលដែលបង្កដោយគ្រោះថ្នាក់ចៃដន្យ។ ជាមួយនឹងដំណោះស្រាយរួមបញ្ចូលទាំងអស់ពី **អេ អាយ អេ ខេមបូឌា** នាងមិនជួបប្រទះបញ្ហាហិរញ្ញវត្ថុក្នុងអំឡុងពេលព្យាបាលរបស់នាងនៅក្នុងមន្ទីរពេទ្យនោះទេ។ |
| **លោក វិចិត្រា មានអាយុ 35 ឆ្នាំ** ជាអ្នកគ្រប់គ្រងថ្នាក់កណ្តាលម្នាក់។ គាត់បានរងរបួសដោយជណ្តើរយន្តនៅកន្លែងធ្វើការ ដែលបណ្តាលឱ្យគាត់ការបាត់បង់ម្រាមទាំងបួន និង មេដៃមួយនៃដៃម្ខាង។ | លោក វិចិត្រា ទទួលបានការចំណាយសរុបចំនួន **15,000** ដុល្លារអាមេរិក ឬស្មើនឹង **50%** នៃអត្ថប្រយោជន៍លើពិការភាពដែលបង្កដោយគ្រោះថ្នាក់ចៃដន្យ (ការបាត់បង់ម្រាមទាំងបួន និងមេដៃមួយនៃដៃម្ខាងដោយសារហេតុការណ៍ចៃដន្យ)។<br>ជាមួយនឹងទឹកប្រាក់នៃជំនួយហិរញ្ញវត្ថុនេះ លោក វិចិត្រា អាចបន្ធូរបន្ថយការចំណាយផ្នែកហិរញ្ញវត្ថុរបស់គាត់បាន។ |
| **លោក ថារ៉េត មានអាយុ 48 ឆ្នាំ** ជានាយកប្រតិបត្តិជាន់ខ្ពស់ មានដំណើរបេសកកម្មទៅខេត្ត។ គាត់បានស្លាប់បន្ទាប់ពីជួបគ្រោះថ្នាក់ចរាចរណ៍មួយ។ | បន្ទាប់ពីមរណភាពរបស់លោក ថារ៉េត គ្រួសាររបស់លោកទទួលបានទឹកប្រាក់ចំនួន **50,000** ដុល្លារអាមេរិក ឬស្មើនឹង **100%** នៃអត្ថប្រយោជន៍លើមរណភាពដែលបង្កដោយគ្រោះថ្នាក់ចៃដន្យ ពី **អេ អាយ អេ ខេមបូឌា** សម្រាប់ជាជំនួយហិរញ្ញវត្ថុដល់គ្រួសាររបស់គាត់។ |

# និតិវិធីនៃការទាមទារសំណង

## លក្ខណ:សម្បត្តិរបស់អ្នកដាក់ពាក្យស្នើសុំទាមទារសំណង

អ្នកដាក់ពាក្យស្នើសុំទាមទារសំណងអាចជាម្ចាស់បណ្ណសន្យាធានារ៉ាប់រងឬជាអ្នកទទួលផលដែលត្រូវបានចាត់តាំងដោយម្ចាស់ បណ្ណសន្យាធានារ៉ាប់រង។ អ្នកទាមទារសំណងត្រូវមានអាយុយ៉ាងតិច **18 ឆ្នាំ**។

## សេចក្តីជូនដំណឹងអំពីការទាមទារសំណង

ការជូនដំណឹងអំពីការទាមទារសំណងត្រូវតែផ្តល់ជូនក្រុមហ៊ុនក្នុងរយៈពេល **90 (កៅសិប) ថ្ងៃ** ចាប់ពីថ្ងៃកើតឡើងនៃព្រឹត្តិការណ៍គ្រោះថ្នាក់ចៃដន្យដែលអាចធ្វើការទាមទារសំណងទៅតាមបណ្ណសន្យាធានារ៉ាប់រងនៅការិយាល័យ អេ អាយ អេ ខេមបូឌា ឬទាក់ទងសេវាអតិថិជន **086 999 242**។

## ឯកសារចាំបាច់ ឬភស្តុតាងបញ្ជាក់

- **ភស្តុតាងនៃមរណភាព និងពិការភាពដែលបង្កដោយគ្រោះថ្នាក់ចៃដន្យ**
  នៅពេលដែលបានទទួលការជូនដំណឹងនេះ ទម្រង់បែបបទសម្រាប់ការទាមទារសំណងនឹងត្រូវបានផ្តល់ជូនអ្នកដាក់ពាក្យស្នើសុំទាមទារសំណងក្នុងប្រមូលផ្តុំភស្តុតាងនៃមរណភាព និងពិការភាពដែលបង្កដោយគ្រោះថ្នាក់ចៃដន្យក្នុងរយៈពេល **24 (ម្ភៃបួន) ម៉ោង**។

- **ភស្តុតាងនៃការទទួលបានអត្ថប្រយោជន៍លើការព្យាបាលដែលបង្កដោយគ្រោះថ្នាក់ចៃដន្យ**
  ភស្តុតាងនៃគ្រោះថ្នាក់ចៃដន្យគឺមានភាពចាំបាច់ដែលតម្រូវអោយដាក់រួមបញ្ចូល ប៉ុន្តែក៏មិនតម្រូវតែច្បាប់ដើមនៃឯកសារនោះដែលដូចជា៖ បង្កាន់ដៃពិនិត្យព្យាបាល វិញ្ញាបនបត្រវេជ្ជសាស្រ្ត លិខិតចេញពីម័ន្ទីពេទ្យ និងឯកសារវេជ្ជសាស្រ្ត ផ្សេងៗជាមួយនឹងទម្រង់បែបបទទាមទារសំណងដាក់ជូនទៅក្រុមហ៊ុន។ រាល់ឯកសារវេជ្ជសាស្រ្តទាំងអស់ត្រូវតែទទួលបានមកពីមណ្ឌលវេជ្ជសាស្រ្តដែលមានអាជ្ញាប័ណ្ណស្របច្បាប់ក្នុងការផ្តត់ផ្គង់ការព្យាបាលនៅក្នុងប្រទេស។

### រយៈពេលក្នុងការទាមទារសំណង

ការទាមទារសំណងត្រូវបានធ្វើឡើងក្នុងរយៈពេល **15 (ដប់ប្រាំ)** ថ្ងៃធ្វើការ បន្ទាប់ពីទទួលបានឯកសារចាំបាច់ពេញលេញរួចរាល់។

### វិធីសាស្រ្តក្នុងការទាមទារសំណង

ចំនួនទឹកប្រាក់សំណងនឹងត្រូវដាក់បញ្ចូលទៅក្នុងគណនីធនាគារដែលបានផ្តល់ដោយអ្នកទាមទារសំណងទៅកាន់ក្រុមហ៊ុន។

## ទទួលបានសំណើរធានារ៉ាប់រងរបស់អ្នកនៅថ្ងៃនេះ!


ទំនាក់ទំនងមកទីប្រឹក្សាផែនការជីវិត អេ អាយ អេ

086 999 242

AIA.COM.KH

AIA CAMBODIA

**AIA Cambodia** Telegram Channel

# អត្ថប្រយោជន៍ធានារ៉ាប់រង

| ប្រភេទអត្ថប្រយោជន៍ធានារ៉ាប់រង | ទឹកប្រាក់ធានារ៉ាប់រង |
|---|---|
| **អត្ថប្រយោជន៍លើមរណភាពដែលបង្កដោយគ្រោះថ្នាក់ចៃដន្យ** | 100% |
| **អត្ថប្រយោជន៍លើពិការភាពដែលបង្កដោយគ្រោះថ្នាក់ចៃដន្យ** | 100% |
| ការបាត់បង់ជើង ឬដៃទាំងសងខាង | |
| ការបាត់បង់សមត្ថភាពក្នុងការមើលឃើញ ការស្តាប់លឺ និងការនិយាយ | |
| ការបាត់បង់ដៃទាំងសងខាង ឬ ម្រាមទាំងអស់ និង មេដៃទាំងសងខាង | |
| ការបាត់បង់ទាំងស្រុងនៃសមត្ថភាពក្នុងការមើលឃើញនៃភ្នែកទាំងសងខាង | |
| ពិការភាពជាអចិន្ត្រៃយ៍ | |
| របួសដែលបណ្តាលឱ្យគេងមួយកន្លែងជាអចិន្ត្រៃយ៍ | |
| ការបាត់បង់ដៃម្ខាងពីស្មា | 50% |
| ការបាត់បង់ដៃម្ខាងនៅចន្លោះស្មា និង កែងដៃ | |
| ការបាត់បង់ដៃម្ខាងពីកែងដៃ | |
| ការបាត់បង់ដៃម្ខាងនៅចន្លោះកែងដៃ និង កដៃ | |
| ការបាត់បង់ដៃម្ខាងពីកដៃ | |
| ការបាត់បង់ជើងម្ខាងពីត្រគាក | |
| ការបាត់បង់ជើងម្ខាងនៅចន្លោះជង្គង់ និងត្រគាក | |
| ការបាត់បង់ជើងម្ខាងក្រោមជង្គង់ | |
| ការបាត់បង់ភ្នែកម្ខាងទាំងស្រុង | |
| ការបាត់បង់សមត្ថភាពក្នុងការមើលឃើញនៃភ្នែកម្ខាងលើកលែងតែ | |
| ការមើលឃើញពន្លឺ | |
| ការបាត់បង់កែវភ្នែកម្ខាង | |
| ការបាត់បង់ម្រាមទាំងបួន និង មេដៃនៃដៃម្ខាង | |
| ការបាត់បង់ម្រាមទាំងបួននៃដៃទាំងសងខាង | 40% |
| ការបាត់បង់មេដៃនៃដៃម្ខាង | |
| • 2 ថ្នាំង | 25% |
| • 1 ថ្នាំង | 10% |
| ការបាត់បង់ម្រាមដៃចង្អុលនៃដៃម្ខាង | |
| • 3 ថ្នាំង | 10% |
| • 2 ថ្នាំង | 8% |
| • 1 ថ្នាំង | 4% |
| ការបាត់បង់ម្រាមដៃកណ្តាល ម្រាមដៃនាង កូនដៃនៃដៃម្ខាង | |
| • 3 ថ្នាំង | 6% |
| • 2 ថ្នាំង | 4% |
| • 1 ថ្នាំង | 2% |
| ការបាត់បង់ឆ្អឹងនៃប្រអប់ដៃ | |
| • ម្រាមទី1 ឬទី 2 | 3% |
| • ម្រាមទី3 ទី4 ឬទី 5 | 2% |
| ការបាត់បង់ម្រាមជើងនៃជើងតែម្ខាង | |
| • ម្រាមទាំងអស់ | 15% |
| • មេជើង 2 ថ្នាំង | 5% |
| • មេជើង 1 ថ្នាំង | 2% |
| • ប្រសិនបាត់បង់ម្រាមជើងច្រើនជាងមួយ ក្រៅពីមេជើង | 1% |
| ការបាត់បង់សមត្ថភាពក្នុងការស្តាប់លឺ | |
| • ត្រចៀកទាំងសងខាង | 75% |
| • ត្រចៀកម្ខាង | 15% |
| ការបាត់បង់សមត្ថភាពក្នុងការនិយាយ | 50% |
| **អត្ថប្រយោជន៍លើការព្យាបាលដែលបង្កដោយគ្រោះថ្នាក់ចៃដន្យ** | 10% |

# ករណីមិនធានា

## 1. ករណីមិនធានាសម្រាប់អត្ថប្រយោជន៍លើមរណភាព និង អត្ថប្រយោជន៍លើពិការភាពដែលបង្កដោយគ្រោះថ្នាក់ចៃដន្យ

ផលិតផលធានារ៉ាប់រងបន្ថែមនេះនឹងមិនធានាលើមរណភាព ឬពិការភាពដោយសារគ្រោះថ្នាក់ចៃដន្យ ដែលកើតឡើងដោយផ្ទាល់ ឬដោយប្រយោល ទាំងស្រុង ឬដោយផ្នែក ពីករណីណាមួយខាងក្រោមនេះ៖

1. ការធ្វើអត្តឃាត ឬប៉ុនប៉ងធ្វើអត្តឃាត ឬធ្វើឱ្យរបួសខ្លួនឯងណាមួយទោះស្ថិតក្នុងស្ថានភាពផ្លូវចិត្តប្រក្រតី ឬមិនប្រក្រតីក៏ដោយ ឬ
2. ការប្រព្រឹត្ត ឬការប៉ុនប៉ងប្រព្រឹត្តនូវបទល្មើសព្រហ្មទណ្ឌ ដោយម្ចាស់បណ្ណសន្យារ៉ាប់រង ឬដោយសមាជិកអ្នកត្រូវបានធានារ៉ាប់រង ឬអ្នកទទួលផល ឬ
3. ការរលូតកូន ការមានផ្ទៃពោះ ការសម្រាលកូន ឬផលវិបាកក្នុងកំឡុងពេលមានផ្ទៃពោះ លើកលែងតែព្រឹត្តិការណ៍បែបនេះត្រូវបានបង្កឡើងដោយសារគ្រោះថ្នាក់ចៃដន្យ
4. ឧបទ្ទវហេតុដែលកើតឡើងខណៈពេលដែល ឬដោយសារសមាជិកអ្នកត្រូវបានធានារ៉ាប់រងស្ថិតក្រោមឥទ្ធិពលជាតិស្រវឹង ឱសថដែលមិនបានចេញដោយវេជ្ជបញ្ជា ឬគ្រឿងញៀនខុសច្បាប់ផ្សេងៗ ឬ
5. ទម្រង់ណាមួយនៃជំងឺផ្លូវចិត្ត ឬវិកលចរិក
6. រោគក្លន ការបង្ករោគដោយផ្សិត ឬបាក់តេរី (លើកលែងតែការកើតខ្ទុះដែលកើតចេញពីមុខរបួស ឬដំបៅដែលបង្កដោយគ្រោះថ្នាក់) ឬ
7. របួសដែលបណ្តាលមកពីសត្វល្អិតខាំ រួមបញ្ចូល ប៉ុន្តែមិនកំណត់ត្រឹម មូសខាំ និងឃ្មុំទិច ឬ
8. ការចូលរួមក្នុងកីឡាអាជីព ឬសកម្មភាពដែលមានគ្រោះថ្នាក់ដូចជា ការហក់លោតពីទីអាកាសខ្ពស់ (skydiving) ការលោតឆ័ត្រយោង (parachuting) ការលោតពីទីខ្ពស់ដោយប្រើខ្សែរព្វរ (bungee jumping) ការឡើងភ្នំ ប្រណាំង ការជ្រមុជទឹក (Scuba diving) ការប្រណាំងក្នុងទម្រង់ណាមួយ ឬ
9. ការចូលរួមក្នុងការធ្វើដំណើរតាមផ្លូវអាកាស លើកលែងតែក្នុងករណីសមាជិកអ្នកត្រូវបានធានារ៉ាប់រងគឺជាអ្នកដំណើរធម្មតាក្នុងយន្តហោះពាណិជ្ជកម្មដែលចុះបញ្ជីការត្រឹមត្រូវដែលធ្វើការជាប្រចាំតាមគន្លងផ្លូវអាកាស ឬខណៈពេលដែលសមាជិកអ្នកត្រូវបានធានារ៉ាប់រងធ្វើការជាអ្នកបើកយន្តហោះ ឬអ្នកបម្រើលើយន្តហោះណាមួយ ឬ
10. កូដកម្ម កុប្បកម្ម ចលាចលសង្គម ការបះបោរ ឬសកម្មភាពភេរវជន ឬ
11. សង្គ្រាមដែលបានប្រកាស ឬមិនបានប្រកាស ឬបដិវត្តន៍ ឬ
12. ការចូលបម្រើក្នុងជួរកងទ័ព ក្នុងកំឡុងពេលមានប្រកាស ឬគ្មានប្រកាសសង្គ្រាមក្តី ឬក្រោមបញ្ជាប្រតិបត្តិការសង្គ្រាម ឬការស្តារសណ្តាប់ធ្នាប់សាធារណៈ ឬ
13. អាវុធនុយក្លេអ៊ែរ ចំហាយសាយភាពជាតិវិទ្យុសកម្ម ឬវិទ្យុសកម្មពីឥន្ទនៈនុយក្លេអ៊ែរ ឬកាកសំណល់នុយក្លេអ៊ែរដែលកើតចេញពីចំហេះនៃឥន្ទនៈនុយក្លេអ៊ែរ និងដំណើរការនៃការបំប្លែង ឬការលាយបញ្ចូលគ្នានៃនុយក្លេអ៊ែរ ឬ
14. មរណភាព ឬពិការភាពដោយសារគ្រោះថ្នាក់ចៃដន្យដែលបណ្តាលមកពីជំងឺ ឬមេរោគណាមួយ ឬ
15. ពិការភាពដោយសារគ្រោះថ្នាក់ចៃដន្យដែលបណ្តាលមកពីបញ្ហាផ្លូវកាយឬផ្លូវចិត្តដែលកើតមានមុនកាលបរិច្ឆេទដែលបណ្ណសន្យារ៉ាប់រងមានសុពលភាព ហើយដែលមិនបានបង្ហាញក្នុងពាក្យស្នើសុំ ឬរបាយការណ៍សុខភាព។

# ករណីមិនធានា

## 2. ករណីមិនធានាសម្រាប់អត្ថប្រយោជន៍លើការព្យាបាលដែលបង្កដោយគ្រោះថ្នាក់ចៃដន្យ

ផលិតផលធានារ៉ាប់រងបន្ថែមនេះនឹងមិនធានាលើការព្យាបាលលើរបួសស្នាម ដែលកើតឡើងដោយផ្ទាល់ ឬដោយប្រយោល ទាំងស្រុង ឬដោយផ្នែក ពីករណីណាមួយខាងក្រោមនេះ៖

1. ការធ្វើអត្តឃាត ឬប៉ុនប៉ងធ្វើអត្តឃាត ឬធ្វើឱ្យរបួសខ្លួនឯងណាមួយទោះស្ថិតក្នុងស្ថានភាពផ្លូវចិត្តប្រក្រតី ឬមិនប្រក្រតីក៏ដោយ ឬ
2. បទល្មើសព្រហ្មទណ្ឌដែលបានប្រព្រឹត្ត ឬប៉ុនប៉ងប្រព្រឹត្តដោយម្ចាស់បណ្ណសន្យារ៉ាប់រង ឬដោយសមាជិកអ្នកត្រូវបានធានារ៉ាប់រង ឬអ្នកទទួលផល ឬ
3. ការរលូតកូន ការមានផ្ទៃពោះ ការសម្រាលកូនឬផលវិបាកក្នុងកំឡុងពេលមានផ្ទៃពោះ ឬ
4. ឧបទ្ទវហេតុដែលកើតឡើងខណៈពេលដែល ឬដោយសារសមាជិកអ្នកត្រូវបានធានារ៉ាប់រងស្ថិតក្រោមឥទ្ធិពលជាតិស្រវឹង ឱសថដែលមិនបានចេញដោយវេជ្ជបញ្ជា ឬគ្រឿងញៀនខុសច្បាប់ផ្សេងៗ ឬ
5. ទម្រង់ណាមួយនៃជំងឺផ្លូវចិត្តឬវិកលចរិក ឬ
6. រោគក្លន ការបង្ករោគដោយផ្សិត ឬបាក់តេរី (លើកលែងតែការកើតខ្ទុះ ដែលកើតចេញពីមុខរបួស ឬដំបៅដែលបង្កដោយគ្រោះថ្នាក់) ឬ
7. របួសដែលបណ្តាលមកពីសត្វល្អិតខាំ រួមបញ្ចូល ប៉ុន្តែមិនកំណត់ត្រឹម មូសខាំ និងឃ្មុំទិច ឬ
8. ការចូលរួមក្នុងកីឡាអាជីព ឬសកម្មភាពដែលមានគ្រោះថ្នាក់ដូចជា ការហក់លោតពីទីអាកាសខ្ពស់ (skydiving) ការលោតឆ័ត្រយោង (parachuting) ការលោតពីទីខ្ពស់ដោយប្រើខ្សែរព្វរ (bungee jumping) ការឡើងភ្នំ ប្រណាំង ការជ្រមុជទឹក (Scuba diving) ការប្រណាំងក្នុងទម្រង់ណាមួយ ឬ
9. កូដកម្ម កុប្បកម្ម ចលាចលសង្គម ការបះបោរ ឬសកម្មភាពភេរវជន ឬ
10. សង្គ្រាមដែលបានប្រកាស ឬមិនបានប្រកាស ឬបដិវត្តន៍ ឬ
11. ការចូលបម្រើក្នុងជួរកងទ័ព ក្នុងកំឡុងពេលមានប្រកាស ឬគ្មានប្រកាសសង្គ្រាមក្តី ឬក្រោមបញ្ជាប្រតិបត្តិការសង្គ្រាម ឬការស្តារសណ្តាប់ធ្នាប់សាធារណៈ ឬ
12. អាវុធនុយក្លេអ៊ែរ ចំហាយសាយភាពជាតិវិទ្យុសកម្ម ឬវិទ្យុសកម្មពីឥន្ធនៈនុយក្លេអ៊ែរ ឬកាកសំណល់នុយក្លេអ៊ែរ ដែលកើតចេញពីចំហេះនៃឥន្ធនៈនុយក្លេអ៊ែរ និងដំណើរការនៃការបំប្លែង ឬការលាយបញ្ចូលគ្នានៃនុយក្លេអ៊ែរ ឬ
13. ការព្យាបាលដែលបណ្តាលមកពីជំងឺ ឬមេរោគណាមួយ ឬ
14. ការព្យាបាលមុនកាលបរិច្ឆេទនៃសុពលភាពបណ្ណសន្យារ៉ាប់រង ឬការព្យាបាលដែលបណ្តាលមកពីគ្រោះថ្នាក់ចៃដន្យមុនកាលបរិច្ឆេទនៃសុពលភាពបណ្ណសន្យារ៉ាប់រង ឬ
15. ការព្យាបាលដែលមិនមានភាពចាំបាច់។

**ការិយាល័យកណ្ដាល**

អគារ ជីអាយអេ ថៅអឺរ ជាន់ទី31 ផ្លូវសុភមង្គល ភូមិ14 សង្កាត់ទន្លេបាសាក់
ខណ្ឌចំការមន រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា

**សាខាសៀមរាប**

អគារលេខ 29 និង 30
ផ្លូវហ្សាលដឺហ្គោល សាលាកន្សែង សង្កាត់ស្វាយដង្គំ ទីរួមខេត្តសៀមរាប

**សាខាបាត់ដំបង**

ផ្ទះលេខ 2-6ផ្លូវលេខ 3 ភូមិកម្មករ សង្កាត់ស្វាយប៉ោ ក្រុងបាត់ដំបង ខេត្តបាត់ដំបង

**សាខាកំពង់ចាម**

ភូមិ 15 សង្កាត់កំពង់ចាម ខណ្ឌកំពង់ចាម ខេត្តកំពង់ចាម

**សាខាកំពត**

ផ្លូវលេខ 700 ភូមិ 1ឧសភា សង្កាត់កំពង់កណ្ដាល ក្រុងកំពត ខេត្តកំពត

086 999 242 | AIA.COM.KH | AIA CAMBODIA